ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

សេចក្ដីប្រកាសព័ត៌មាន

# **សម្ដេចតេជោ ហ៊ុន សែន** បានបញ្ចប់ទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្ដេ

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ចប់ទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្ដេ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥ ប្រកបដោយជោគជ័យ និងលទ្ធផលជាផ្លែផ្កា។

ជាកិច្ចចាប់ផ្ដើមនៃដំណើរទស្សនកិច្ច **សម្ដេចតេជោ ប្រធានព្រឹទ្ធសភា** ត្រូវបានទទួលបដិសណ្ឋារកិច្ចដោយ **ឯកឧត្ដម ប្រាបូវ៉ូ ស៊ូប៊ីយ៉ាន់តូ** ប្រធានាធិបតីឥណ្ឌូណេស៊ី ក្នុងកម្រិតខ្ពស់ និងធំបំផុត និងប្រកបដោយបរិយាកាសជាមិត្តភាព និងស្និទ្ធស្នាលក្រៃលែង។ នៅក្នុងជំនួបជាមួយឯកឧត្ដមប្រធានាធិបតី **សម្ដេចតេជោ** បានសម្ដែងការអបអរសាទរសាជាថ្មីចំពោះជ័យជម្នះភ្លូកទឹកភ្លូកដីរបស់**ឯកឧត្ដម ប្រាបូវ៉ូ ស៊ូប៊ីយ៉ាន់តូ** ក្នុងការបោះឆ្នោតប្រធានាធិបតីកន្លងមក ព្រមទាំងបានវាយតម្លៃខ្ពស់ចំពោះចំណងមិត្តភាពកម្ពុជា-ឥណ្ឌូណេស៊ី ដែលជាទំនាក់ទំនងដ៏ជិតស្និទ្ធជាប្រវត្តិសាស្ត្រ ផ្សារភ្ជាប់ដោយអតីតថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងពីរ មកដល់ថ្នាក់ដឹកនាំបច្ចុប្បន្ន ជាពិសេសចំណងមិត្តភាពរវាង**សម្ដេចតេជោ** ជាមួយនឹងឯកឧត្ដមប្រធានាធិបតី។ **ឯកឧត្ដម ប្រាបូវ៉ូ ស៊ូប៊ីយ៉ាន់តូ** បានបញ្ជាក់ថា ជាកិត្តិយសណាស់ចំពោះវត្តមានរបស់សម្ដេចតេជោ នៅឥណ្ឌូណេស៊ី ពីព្រោះសម្ដេចតេជោ ជារដ្ឋបុរស ប្រកបដោយទស្សនវិស័យ និងបទពិសោធដឹកនាំប្រទេសយូរឆ្នាំ។ ថ្នាក់ដឹកនាំទាំងពីរបានឯកភាពបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ ជាពិសេសការធ្វើឱ្យកាន់តែស៊ីជម្រៅថែមទៀតនៃកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខស្បៀងនិងថាមពល ការវិនិយោគ ទេសចរណ៍ ការតភ្ជាប់ផ្លូវអាកាស និងការជំរុញពាណិជ្ជកម្មទ្វេភាគី នៅចំពោះមុខនៃបញ្ហាប្រឈមរបស់ពិភពលោកជាពិសេសសង្គ្រាមពាណិជ្ជកម្មដែលកំពុងស្រួចស្រាល់។

បន្ថែមពីលើការផ្លាស់ប្ដូរទស្សនៈយោបល់ស្ដីពីបញ្ហាតំបន់និងពិភពលោក **សម្ដេចតេជោ** បានលើកឡើងអំពីសារៈសំខាន់ និងបានស្នើសុំការគាំទ្រដល់ការចូលជាសមាជិកពេញសិទ្ធិអាស៊ានរបស់ទីម័រឡេស្ដេ នៅឆ្នាំ២០២៥នេះ ហើយជាការឆ្លើយតប **ឯកឧត្ដមប្រធានាធិបតី** បានផ្ដល់ការគាំទ្រទាំងស្រុងចំពោះសំណើរបស់**សម្ដេចតេជោ** និងបានគូសបញ្ជាក់ថានឹងជួយកៀរគរការគាំទ្រពីបណ្ដាថ្នាក់ដឹកនាំរដ្ឋសមាជិកអាស៊ានផ្សេងៗទៀត។ ចំពោះបញ្ហាមីយ៉ាន់ម៉ា **សម្ដេចតេជោ** បានចែករំលែកនូវបទពិសោធផ្ទាល់របស់កម្ពុជា និងស្នើឱ្យមានការរិះរកមធ្យោបាយបន្ថែមថ្មីក្នុងការបន្តជួយជ្រោមជ្រែងដោះស្រាយបញ្ហាមីយ៉ាន់ម៉ា ដោយសង្កត់ធ្ងន់អំពីតួនាទីស្នូលរបស់អាស៊ាន និងភាពចាំបាច់នៃការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធរបស់មីយ៉ាន់ម៉ា នៅក្នុងការស្វែងរកសន្តិភាព និងការផ្សះផ្សាជាតិ។ គួរកត់សម្គាល់ផងដែរថា ដើម្បីបង្ហាញពីការគាំទ្រយ៉ាងពេញទំហឹងចំពោះ**សម្ដេចតេជោ** ឯកឧត្ដមប្រធានាធិបតី បានភ្ជាប់ការសន្ទនាតាមប្រព័ន្ធវីដេអូជាមួយឯកឧត្ដមនាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងជាមួយ**សម្ដេចតេជោ** ដើម្បី

ពិគ្រោះយោបល់អំពីបញ្ហាសំខាន់ៗទាំងពីរខាងលើ ហើយឯកឧត្តមនាយករដ្ឋមន្ត្រី ក៏បានឆ្លើយតបជាវិជ្ជមានចំពោះសំណើរបស់សម្តេចផងដែរ។ ការណ៍នេះបានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងយ៉ាងប្រត្យក្សក្នុងកិច្ចការសភាការទូត របស់សម្តេចតេជោ ចំពោះបញ្ហានានា ដែលជាប្រយោជន៍រួមសម្រាប់តំបន់ និងពិភពលោក ជាពិសេសការគាំទ្រយ៉ាងពេញទំហឹង និងឥតងាករេចំពោះការចូលជាសមាជិកពេញសិទ្ធិអាស៊ានរបស់ទីម័រឡេស្តេ។ ជាមួយគ្នានេះ ឯកឧត្តម **ប្រាបូវ៉ូ ស៊ូប៊ីយ៉ាន់តូ** បានបញ្ជាក់ពីការគាំទ្រពេញទំហឹងរបស់ឥណ្ឌូណេស៊ី ចំពោះបេក្ខភាពពីកម្ពុជាជាអគ្គលេខាធិការប្តូរវេននៃអន្តរសភាអាស៊ាន សម្រាប់អាណត្តិថ្មី (២០២៦-២០២៩) ផងដែរ។

នៅក្នុងជំនួបដាច់ដោយឡែកពីគ្នាជាមួយប្រធានរដ្ឋសភា និងព្រឹទ្ធសភាឥណ្ឌូណេស៊ី ភាគីទាំងពីរបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការទូតសភា និងបានឯកភាពបន្តពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរឱ្យកាន់តែសកម្មថែមទៀត ជាពិសេសតាមរយៈសកម្មភាពរបស់ក្រុមមិត្តភាពសភា និងរវាងគណៈកម្មការសភា ក៏ដូចជាការផ្លាស់ប្តូរថ្នាក់ដឹកនាំសភានៃប្រទេសទាំងពីរ។ ភាគីទាំងពីរក៏បានយល់ស្របគ្នាលើការលើកកម្ពស់តួនាទីសភាដែលជំរុញដល់ការគាំទ្ររដ្ឋាភិបាល ក្នុងការរៀបចំបង្កើត និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលធានាក្នុងការផ្តល់ផលប្រយោជន៍និងការចូលរួមយ៉ាងសកម្មពីប្រជាជន និងអ្នកពាក់ព័ន្ធ។ ទន្ទឹមនឹងនេះដែរ តបតាមការផ្តួចផ្តើមគំនិតរបស់**សម្តេចតេជោ** ក្នុងការបង្កើតវេទិកានៃកិច្ចប្រជុំកំពូលព្រឹទ្ធសភាអាស៊ាន ដើម្បីជាយន្តការពិភាក្សា និងផ្លាស់ប្តូរយោបល់ក្នុងចំណោមស្ថាប័នព្រឹទ្ធសភាក្នុងបណ្តាប្រទេសអាស៊ាន លើបញ្ហានានាដែលជាឧត្តមប្រយោជន៍រួមក្នុងតំបន់ និងសកលលោក ក្នុងស្ថានភាពដែលកំពុងមានភាពមិនប្រាកដប្រជា និងប្រែប្រួលខ្លាំងនេះ ឯកឧត្តមប្រធានព្រឹទ្ធសភាឥណ្ឌូណេស៊ី បានគាំទ្រយ៉ាងពេញទំហឹងចំពោះគំនិតផ្តួចផ្តើម ហើយសន្យានឹងធ្វើការរួមគ្នាជាមួយ**សម្តេចតេជោ** ដើម្បីរៀបចំវេទិកានេះឱ្យលេចចេញជារូបរាងឡើង។

នៅក្នុងជំនួបរួមជាមួយអគ្គលេខាធិការអាស៊ាន គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន និងឯកអគ្គរដ្ឋទូតទីម័រឡេស្តេប្រចាំអាស៊ាន នៅលេខាធិការដ្ឋានអាស៊ាន **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** បានរំឭកអំពីកិច្ចខិតខំរបស់កម្ពុជាក្នុងការបំពេញតួនាទីជាសមាជិកដ៏សកម្មមួយរបស់អាស៊ាន និងការប្តេជ្ញាឥតងាករេ ក្នុងការបន្តរួមចំណែកលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់ ដើម្បីសម្រេចឱ្យបាននូវគោលដៅរួមអាស៊ាន។ **សម្តេចតេជោ** ក៏បានផ្តល់បាឋកថាពិសេសស្តីពី **"កម្ពុជា និងអាស៊ាន, អាស៊ាន និងពិភពលោក"** ដែលជាវិភាគទានដ៏សំខាន់ក្នុងការអបអរសាទរខួប ២៦ឆ្នាំ នៃការចូលជាសមាជិកអាស៊ានរបស់កម្ពុជា ដោយមានការចូលរួមពីមន្ត្រីនៃលេខាធិការដ្ឋានអាស៊ាន, តំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន, អង្គទូតប្រចាំឥណ្ឌូណេស៊ីនិងប្រចាំអាស៊ាន, ថ្នាក់ដឹកនាំនិងអតីតថ្នាក់ដឹកនាំនៃក្រសួង/ស្ថាប័នរដ្ឋរបស់ឥណ្ឌូណេស៊ី និងតំណាងអង្គភាពនានារបស់អាស៊ានប្រមាណជាង ៤០០នាក់។ ក្នុងសុន្ទរកថាស្វាគមន៍ ឯកឧត្តម កៅ គឹមហួន អគ្គលេខាធិការអាស៊ាន បានថ្លែងថា ឯកឧត្តមពិតជាមានកិត្តិយសបំផុតចំពោះវត្តមានរបស់**សម្តេចតេជោ** នៅលេខាធិការដ្ឋានអាស៊ាន ដែលជារដ្ឋបុរស និងជាថ្នាក់ដឹកនាំប្រកបដោយទស្សនវិស័យ និងដ៏មានឥទ្ធិពលក្នុងតំបន់ ដែលបានលះបង់គ្រប់បែបយ៉ាង ដើម្បីផលប្រយោជន៍ ការកសាងសន្តិភាព ស្ថិរភាព និងវិបុលភាព សម្រាប់កម្ពុជា តំបន់ និងពិភពលោក។ **សម្តេចតេជោ** បានសម្តែងការគោរពដល់ស្ថាបនិកដ៏ឧត្តុង្គឧត្តមរបស់អាស៊ាន ព្រមទាំងអតីតមេដឹកនាំអាស៊ានទាំងឡាយ ដែលបានបូជាកម្លាំងកាយ ចិត្ត ស្មារតី និងបញ្ញាញាណប្រកបដោយគតិបណ្ឌិត ក្នុងការកសាង និងការរៀបចំរចនាសម្ព័ន្ធនិងនិម្មាបនកម្មតំបន់ ដោយយកសន្តិភាព និងប្រជាជនជាស្នូល។ **សម្តេចតេជោ** បាន

សម្តែងការគោរពដល់ស្ថាបនិកដ៏ឧត្តុង្គឧត្តមរបស់អាស៊ាន ព្រមទាំងអតីតមេដឹកនាំអាស៊ានទាំងឡាយ ដែលបានបូជាកម្លាំងកាយ ចិត្ត ស្មារតី និងបញ្ញាញាណប្រកបដោយគតិបណ្ឌិត ក្នុងការកសាង និងការរៀបចំរចនាសម្ព័ន្ធនិងនិម្មាបនកម្មតំបន់ ដោយយកសន្តិភាព និងប្រជាជនជាស្នូល។ **សម្តេចតេជោ** បានរំឭកឡើងវិញអំពីការចូលរួមយ៉ាងសកម្មរបស់អាស៊ាន ក្នុងដំណើរការសន្តិភាពនៅកម្ពុជា ជាពិសេសឥណ្ឌូណេស៊ី និងថៃ ព្រមទាំងបានចែករំលែកការយល់ដឹងអំពីប្រវត្តិនិងបទពិសោធនៃការដឹកនាំកម្ពុជា រហូតបានក្លាយជាសមាជិកអាស៊ាន នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ និងការធ្វើជាប្រធានអាស៊ានទាំង៣លើក។ **សម្តេចតេជោ** បានគូសរំលេចនូវតួនាទីរបស់អាស៊ាន នៅក្នុងនិម្មាបនកម្មអភិបាលកិច្ចកម្រិតពិភពលោក តាមរយៈការពង្រឹងសមត្ថភាពខ្លួន និងការពង្រឹងអន្តរកម្មរបស់អាស៊ាន ជាមួយស្ថាប័នពហុភាគីដែលមានឥទ្ធិពល។ សម្រាប់អនាគត **សម្តេចតេជោ** បានគូសបញ្ជាក់បន្ថែមថា ជាមួយនឹងទិសដៅត្រឹមត្រូវ អាស៊ាននឹងក្លាយជាប៉ូលមួយដ៏សំខាន់របស់ពិភពលោក ដែលមានភាពបត់បែនខ្ពស់ និងមានភាពជាក់ស្តែងនិយម ដែលមិនយកប្រទេស ឬតំបន់ណាមួយជាសត្រូវ ហើយក៏មិនក្លាយជាវេទិកានៃសង្គ្រាមតួអង្គតំណាង។

ជាមួយគ្នាដែរនេះ **សម្តេចតេជោ** ក៏បានបន្តអញ្ជើញថ្លែងបាឋកថា ក្រោមប្រធានបទស្តីពី **«ទស្សនៈ និងបទពិសោធនៃកិច្ចខិតខំកសាងសន្តិភាពនៅកម្ពុជា»** នៅវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា ដោយមានអ្នកចូលរួមប្រមាណជាង ២០០ នាក់។ នៅក្នុងបាឋកថា ដែលមានអត្ថន័យជាប្រវត្តិសាស្ត្រនេះ **សម្តេចតេជោ** បានរំលឹកឡើងវិញអំពីសោកនាដកម្ម និងវិនាសកម្ម នៃសង្គ្រាមនៅកម្ពុជារយៈពេលជាង ៣ ទសវត្សរ៍ ជាពិសេសការបំផ្លិចបំផ្លាញប្រទេសដល់ឫសគល់ទាំងស្រុង និងការកាប់សម្លាប់យ៉ាងឃោរឃៅចំពោះប្រជាជនស្លូតត្រង់ជាង ៣ លាននាក់ក្នុងអំឡុងរបបប្រល័យពូជសាសន៍ប៉ុលពត ព្រមទាំងបានរំលឹកអំពីប្រវត្តិក្នុងការតស៊ូ និងការលះបង់ពលិកម្មគ្រប់បែបយ៉ាងរបស់សម្តេច រហូតដល់យកជីវិតធ្វើជាដើមទុនដល់ទៅពីរដងក្នុងមួយជីវិត ក្នុងដំណើរការតស៊ូសង្គ្រោះជាតិទាំងមូល ការពារជាតិមិនឱ្យធ្លាក់ទៅក្នុងរបបប្រល័យពូជសាសន៍វិញ ស្វែងរកសន្តិភាព និងផ្សះផ្សាជាតិ ជាពិសេសបានដឹកនាំកម្ពុជាចេញពីបាតដៃទទេ រហូតដល់មានការរីកចម្រើនលូតលាស់ជឿនលឿនលើគ្រប់វិស័យរហូតមកដល់បច្ចុប្បន្ន។ **សម្តេចតេជោ** ក៏បានចែករំលែកអំពីការអនុវត្តនយោបាយឈ្នះ-ឈ្នះ ដែលសម្តេចបានផ្តួចផ្តើម និងបានធ្វើឱ្យកម្ពុជាសម្រេចបានសុខសន្តិភាព និងឯកភាពទឹកដី នៅឆ្នាំ១៩៩៨។ នេះគឺជាសន្តិភាពពេញលេញ យូរអង្វែង ដែលកម្ពុជាពុំធ្លាប់ស្គាល់ទាល់តែសោះ ក្នុងអំឡុងពេល ៥០០ ឆ្នាំ ចុងក្រោយនេះ ហើយជាសន្តិភាពដែលបានមកដោយលំបាកបំផុត និងដែលមានគុណតម្លៃមិនអាចកាត់ថ្លៃបាន។ សម្តេច ក៏បានចែករំលែកអំពីមេរៀនសំខាន់ៗ និងបទពិសោធក្នុងការកសាងសន្តិភាព ការផ្សះផ្សា និងបង្រួបបង្រួមជាតិដោយគ្មានប្រើប្រាស់គ្រាប់កាំភ្លើង និងការបង្ហូរឈាម ហើយដែលមានលក្ខណៈយូរអង្វែង និងមានបរិយាបន្ន រួមមាន៖ (១) ការធ្វើជាម្ចាស់លើជោគវាសនាប្រទេសជាតិ, (២) តួនាទីរបស់សហគមន៍អន្តរជាតិ ក្នុងការរួមគ្នាការពារសន្តិភាពដែលមានស្រាប់ ជាជាងស្វែងរក ឬកសាងសន្តិភាពដែលបាត់បង់, (៣) ការថែរក្សា និងបន្តចាក់ឫសសន្តិភាពឱ្យបានរឹងមាំ និងយូរអង្វែងក្នុងសង្គមជាតិ ព្រោះថា ទោះជាសម្រេចបានសន្តិភាពក៏ដោយ ក៏សន្តិភាពមិនអាចស្ថិតនៅគង់វង្សយូរអង្វែងបានទេ ប្រសិនបើគ្មានមូលដ្ឋានគ្រឹះក្នុងការថែរក្សាសន្តិភាព យុត្តិធម៌សង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន។

ក្នុងអំឡុងពេលស្នាក់នៅទីក្រុងហ្សាការតា **សម្តេចតេជោ** ក៏បានទទួលជួប ឯកឧត្តម **បណ្ឌិត ម៉ូហាម៉ាត់ យូសុស កាឡា** (MUHAMMAD JUSUF KALLA) អតីតអនុប្រធានាធិបតីឥណ្ឌូណេស៊ី

ប្រធានប្រតិបត្តិអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្ដាលអាស៊ី-ប៉ាស៊ីហ្វិក ដើម្បីសម្ដែងការគួរសម និងពិភាក្សាការងារប្រកបដោយបរិយាកាសស្និទ្ធស្នាល។ **សម្ដេចតេជោ** ក៏បានអនុញ្ញាតជូនសាស្ត្រាចារ្យបណ្ឌិត **ដាតុ ស្រ៊ី តាហៀ** សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់របស់ប្រធានាធិបតីឥណ្ឌូណេស៊ី ស្ថាបនិកក្រុមហ៊ុន Mayapada Group, ប្រធានក្រុមហ៊ុន ប៊ី ប៊ី អិច គ្រឌីត យូនៀន និងប្រធានក្រុមហ៊ុន ភីធី សូណា ធូផាស ធូរីសេមិន ដាសទ្រី ធីប៊ីខេ ចូលជួបសម្ដែងការគួរសមផងដែរ។

ក្នុងអំឡុងទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ **សម្ដេចតេជោ ប្រធានព្រឹទ្ធសភា** មានជំនួបដាច់ដោយឡែកពីគ្នា ជាមួយឯកឧត្ដម **ចូហ្សេ រ៉ាម៉ូស អរតា** ប្រធានាធិបតី ឯកឧត្ដម **កៃ រ៉ាឡា សាណាណា ហ្គូសម៉ៅ** នាយករដ្ឋមន្ត្រី និងលោកជំទាវ **ម៉ារៀ ហ្វើណាន់ដា ឡៃ** ប្រធានរដ្ឋសភា។ ក្នុងឱកាសនៃជំនួបទាំងបីនេះ ថ្នាក់ដឹកនាំទីម័រឡេស្តេបានសម្ដែងនូវការស្វាគមន៍យ៉ាងកក់ក្ដៅបំផុតចំពោះ**សម្ដេចតេជោ** និងគណៈប្រតិភូ និងបានសម្ដែងការដឹងគុណចំពោះមិត្តភាពដ៏វិសេស ព្រមទាំងការគាំទ្រដ៏មោះមុតខ្លាំងក្លារបស់**សម្ដេចតេជោ** ចំពោះប្រជាជន និងរដ្ឋាភិបាលទីម័រឡេស្តេ តាំងពីដើមរៀងមក ដែលបានរួមចំណែកឱ្យទីម័រឡេស្តេអាចក្លាយជាអ្នកសង្កេតការណ៍របស់អាស៊ាន កាលពីឆ្នាំ២០២២ នៅពេលកម្ពុជាធ្វើជាប្រធានប្ដូរវេនអាស៊ាន និងការបន្តខិតខំជួយជ្រោមជ្រែង ដើម្បីឱ្យទីម័រឡេស្តេបានចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ាននាពេលខាងមុខ។ **សម្ដេចតេជោ** បានសម្ដែងនូវសេចក្ដីរីករាយ និងអរគុណចំពោះការទទួលបដិសណ្ឋារកិច្ចដ៏អស្ចារ្យ និងក្នុងកម្រិតដ៏ខ្ពស់បំផុតជូនចំពោះ**សម្ដេចតេជោ** និងគណៈប្រតិភូ ដែលបង្ហាញអំពីចំណងមិត្តភាពដ៏រឹងមាំ ជាពិសេសទំនាក់ទំនងដ៏ស្និទ្ធស្នាលបំផុតរវាងថ្នាក់ដឹកនាំ នៃប្រទេសទាំងពីរ។ ថ្នាក់ដឹកនាំទាំងពីរបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពនៃទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធ ចាប់តាំងពីពេលបង្កើតទំនាក់ទំនងការទូតនៃប្រទេសទាំងពីរនៅឆ្នាំ២០០២។ **សម្ដេចតេជោ**បានសម្ដែងនូវការពេញចិត្តចំពោះទំនាក់ទំនងកម្ពុជា-ទីម័រឡេស្តេ នៅក្នុងក្របខ័ណ្ឌអន្តរជាតិ ទោះបីជាសេដ្ឋកិច្ចពាណិជ្ជកម្ម នៅមានកម្រិតតិចតួចនៅឡើយ។ ភាគីទាំងពីរបានឯកភាពជំរុញទំនាក់ទំនងដែលល្អស្រាប់ឱ្យកាន់តែរីកចម្រើនមួយកម្រិតទៀត តាមរយៈការបន្តផ្លាស់ប្ដូរទស្សនកិច្ចគ្រប់កម្រិត ការលើកកម្ពស់ការទូតសភា និងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរសភា ការពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យដែលមានសក្ដានុពលជាច្រើន រួមមាន ពាណិជ្ជកម្ម, វិនិយោគ, រ៉ែ, ថាមពល, អប់រំ, ទេសចរណ៍, ការតភ្ជាប់ និងប្រៃសណីយ៍។ ឆ្លៀតក្នុងឱកាសនោះ **សម្ដេចតេជោ** បានគូសរំលេចអំពីចំណុចខ្លាំង និងចំណុចខ្សោយរវាងប្រទេសទាំងសងខាង ដោយទីម័រឡេស្តេមានចំណុចខ្លាំងខាងសន្តិសុខថាមពល រីឯកម្ពុជាមានចំណុចខ្លាំងខាងសន្តិសុខស្បៀង ដែលភាគីទាំងពីរអាចជួយបំពេញតម្រូវការឱ្យគ្នា។ **សម្ដេចតេជោ**បានស្នើថា រដ្ឋាភិបាលទាំងពីរគួរតែពង្រីកនូវកិច្ចសហការជាមួយគ្នា ដើម្បីបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ដោយបង្ហាញក្ដីសង្ឃឹមថា រដ្ឋាភិបាលទាំងពីរ ជាពិសេសនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ អាចបន្តជួបគ្នាក្នុងកិច្ចប្រជុំអាស៊ាននាពេលឆាប់ៗខាងមុខ។ **សម្ដេចតេជោ** បានធ្វើការប្រៀបធៀបអំពីស្ថានភាពសេដ្ឋកិច្ចរវាងទីម័រឡេស្តេ នាពេលបច្ចុប្បន្ន និងស្ថានភាពកម្ពុជា មុនពេលចូលអាស៊ាន នៅឆ្នាំ១៩៩៩ អមជាមួយនឹងជំនឿយ៉ាងមុតមាំថា ប្រទេសសមាជិកអាស៊ានទាំងអស់នឹងទទួលយកទីម័រឡេស្តេជាសមាជិកអាស៊ានពេញសិទ្ធិ។

ក្នុងឱកាសទស្សនកិច្ចនេះដែរ **សម្ដេចតេជោ** បានអញ្ជើញថ្លែងសុន្ទរកថា ក្នុងសម័យប្រជុំពិសេសនៅរដ្ឋសភាទីម័រឡេស្តេ ដោយបានផ្ដោតលើការរឹតចំណងមិត្តភាព និងទំនាក់ទំនងដ៏ជិតស្និទ្ធរវាងកម្ពុជា និងទីម័រឡេស្តេ ព្រមទាំងចែករំលែកបទពិសោធរបស់កម្ពុជា ក្នុងការត្រៀមចូលជាសមាជិកអាស៊ាន និងបន្ទាប់ពីកម្ពុជាបានចូលជាសមាជិកអាស៊ានកាលពី ២៦ឆ្នាំមុន និងទស្សនៈរបស់**សម្ដេចតេជោ** ជុំវិញ

អាស៊ាន និងពិភពលោក ស្របពេលដែលទីម័រឡេស្តេកំពុងត្រៀមខ្លួនក្លាយជាសមាជិកអាស៊ានពេញសិទ្ធិ នាពេលដ៏ឆាប់ខាងមុខនេះ។

នៅមុនបញ្ចប់ដំណើរទស្សនកិច្ច **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** ក៏បានថ្លែងសុន្ទរកថាគន្លឹះ ស្តីពី «**មេរៀនរបស់ សម្តេចតេជោ ហ៊ុន សែន៖ ដំណើរកម្ពុជាពីរបបប្រល័យពូជសាសន៍ និងភាពក្រីក្រ ឆ្ពោះទៅកាន់សេរីភាព និងការរីកចម្រើន**» នៅវិមានប្រធានាធិបតី ដោយមានអ្នកចូលរួមប្រមាណជាង ៣០០នាក់ រួមមានឯកឧត្តមប្រធានាធិបតី ឯកឧត្តមនាយករដ្ឋមន្ត្រី សមាជិកសភា ថ្នាក់ដឹកនាំជាន់ខ្ពស់ អង្គទូត និស្សិត និងសង្គមស៊ីវិលទីម័រឡេស្តេ។ ជាកិច្ចតបស្នងទៅនឹងវិភាគទានដ៏សំខាន់របស់**សម្តេចតេជោ** ក្នុងការជួយគាំទ្រទីម័រឡេស្តេ ជាង ២ទសវត្សរ៍កន្លងមក ជាពិសេសចំពោះការជំរុញទីម័រឡេស្តេបានចូលជាសមាជិកអាស៊ាន ឯកឧត្តមប្រធានាធិបតីទីម័រឡេស្តេ បានបំពាក់គ្រឿងឥស្សរិយយសរបស់ទីម័រឡេស្តេ Grand Collar of the Order of Timor-Leste ដែលជាគ្រឿងឥស្សរិយយសដ៏ខ្ពស់បំផុតក្នុងពិធីដ៏អធិកអធម។

**សម្តេចតេជោ** ក៏បានពាំនាំព្រះរាជបណ្តាំសាកសួរសុខទុក្ខរបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជូនចំពោះប្រធានាធិបតីឥណ្ឌូណេស៊ី និងទីម័រឡេស្តេ។ ជាមួយគ្នានេះដែរ ដើម្បីបន្តពូនជ្រំទំនាក់ទំនង និងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីបន្ថែមទៀត ប្រធានាធិបតី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ក៏ដូចជា ប្រធានាធិបតី នាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ បានទទួលការអញ្ជើញដោយសេចក្តីរីករាយមកបំពេញទស្សនកិច្ចនៅកម្ពុជា តាមពេលវេលាសមស្រប។

គួរកត់សម្គាល់ផងដែរថា នៅគ្រប់ជំនួបជាមួយថ្នាក់ដឹកនាំនៃប្រទេសឥណ្ឌូណេស៊ី និងទីម័រឡេស្តេ **សម្តេចតេជោ** ទទួលបានការគោរពកោតសរសើរពីឥស្សរភាពរបស់**សម្តេចតេជោ** ដោយចាត់ទុក **សម្តេចតេជោ** ជាឥស្សរជនដ៏មានឥទ្ធិពលបំផុតមួយរូប នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជារដ្ឋបុរសចាស់ទុំ និងជាថ្នាក់ដឹកនាំប្រកបដោយបញ្ញាញាណ មានទស្សនៈវែងឆ្ងាយ និងបានសម្តែងការស្ញប់ស្ញែង និងកោតសរសើរអំពីពលិកម្មរបស់**សម្តេចតេជោ** ក្នុងបុព្វហេតុតស៊ូពុះពារគ្រប់ឧបសគ្គរំដោះកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ និងជាស្ថាបនិកកម្ពុជានៅក្នុងប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប។

ទស្សនកិច្ចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាពេលនេះ បានពង្រឹង និងធ្វើឱ្យទំនាក់ទំនងរវាងកម្ពុជា-ឥណ្ឌូណេស៊ី និងរវាង កម្ពុជា-ទីម័រឡេស្តេ កាន់តែស៊ីជម្រៅ និងបានលើកកម្ពស់កិច្ចសហប្រតិបត្តិការពហុភាគី ដែលនឹងរួមចំណែកដល់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាព ក្នុងតំបន់ និងពិភពលោក។

ថ្ងៃ សុក្រ ១៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥